# ច្បាប់

## ស្តីពី

## ច្បាប់បន្ថែមទៅលើ
## ច្បាប់ស្តីពីសវនកម្ម
## នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

នស/រកម/១១០០/១១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ១០/០៣/២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្ម ,នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង

គតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៣ នីតិកាលទី ១ ព្រមទាំងត្រូវបាន ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចថា ស្របនឹងរដ្ឋធម្មនុញ្ញលើកលែងតែបទប្បញ្ញត្តិនៃឃ្លាទី ១ នៃមាត្រា ១ ហើយដែលមាន សេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១.-**

ត្រូវបានបំពេញបន្ថែមជាមាត្រា ៤០ ក្នុងជំពូកទី ៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដូចតទៅ :

**មាត្រា ៤០.-** ក្នុងករណីចាំបាច់ តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា រដ្ឋសភាអាចសម្រេចបង្កើត គណៈកម្មការពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**